ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលឃុំខនីតិសម្បទា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ដែលសរសេរជាអក្សរកាត់ថា (**ម.យ.ន.**) ដើម្បីជាយន្តការមួយក្នុងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

**មាត្រា២ ..**

អនុក្រឹត្យនេះមានគោលដៅ :

- គ្រប់គ្រងអនីតិជនជាប់ឃុំនៅមណ្ឌលយុវនីតិសម្បទា
- ធានាការពារសិទ្ធិ សុវត្ថិភាព និងលើកស្ទួយសុខុមាលភាពរាងកាយនិងស្មារតីរបស់អនីតិជនជាប់ឃុំ ស្របតាមច្បាប់ជាតិ វិធានជាបទដ្ឋានអប្បបរមានៃអង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន និងវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព
- ស្តារនីតិសម្បទាទណ្ឌិត និងធ្វើសមាហរណកម្មទណ្ឌិតដែលបានអនុវត្តទោសរួចហើយទៅក្នុងសង្គម និងសហគមន៍។

**មាត្រា៣ ..**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើមណ្ឌលយុវនីតិសម្បទា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ..**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ:

១- **អនីតិជនជាប់ឃុំ** សំដៅដល់អនីតិជនដែលត្រូវចោទ ជាប់ចោទ ជាប់ពិរុទ្ធ ឬទណ្ឌិត ដែលបានបញ្ជូនទៅឃុំខ្លួននៅក្នុងមណ្ឌលយុវនីតិសម្បទា តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ។

២- **មន្ត្រីឬបុគ្គលិកមណ្ឌលយុវនីតិសម្បទា** សំដៅដល់មន្ត្រីឬបុគ្គលិកដែលបម្រើការងារនៅមណ្ឌលយុវនីតិសម្បទា និងស្ថិតក្នុងក្របខណ្ឌរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៣- **មន្ត្រីពេទ្យមណ្ឌលយុវនីតិសម្បទា** សំដៅដល់មន្ត្រីដែលស្ថិតក្នុងក្របខណ្ឌក្រសួងសុខាភិបាល និងត្រូវបានចាត់តាំងឱ្យមកបម្រើការងារនៅមណ្ឌលយុវនីតិសម្បទា។

៤- **មន្ត្រីសន្តិសុខមណ្ឌលយុវនីតិសម្បទា** សំដៅដល់មន្ត្រីដែលស្ថិតក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ និងត្រូវបានចាត់តាំងឲ្យមកបម្រើការងារនៅមណ្ឌលយុវនីតិសម្បទា។

## ជំពូកទី២

## តួនាទីនិងភារកិច្ចរបស់ ម.យ.ន.

**មាត្រា៥ ._**

**ម.យ.ន.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង ថែរក្សា ការពារអនីតិជនដែលត្រូវឃុំខ្លួន តាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ
- បែងចែកការគ្រប់គ្រងអនីតិជន តាមវ័យ តាមភេទ តាមទោសកំហុស និងចំនួនកំណត់
- គ្រប់គ្រងនិងរក្សាសុវត្ថិភាពបញ្ជី ព្រមទាំងព័ត៌មានពាក់ព័ន្ធទាំងអស់របស់អនីតិជនជាប់ឃុំនៅក្នុង **ម.យ.ន.**
- ផ្តល់សេវាពិគ្រោះយោបល់ អប់រំ កែប្រែ តម្រង់ទិស ព្យាបាលថែទាំសុខភាពផ្លូវកាយនិងផ្លូវចិត្ត
- ផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈស្របតាមតម្រូវការ និងសមត្ថភាពជាក់ស្តែងរបស់អនីតិជន និងស្របតាមទីផ្សារការងារ
- ធ្វើសមាហរណកម្មទណ្ឌិតដែលបានអនុវត្តទោសរួចហើយ ទៅក្នុងសង្គមនិងសហគមន៍វិញ
- លើកកម្ពស់និងបង្កើនកិច្ចសហការ ជាមួយក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីធានាការការពារសិទ្ធិ សុវត្ថិភាព សុខុមាលភាពរាងកាយនិងស្មារតីរបស់អនីតិជនជាប់ឃុំ ស្របតាមច្បាប់ជាតិ វិធានជាបទដ្ឋានអប្បបរមានៃអង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន និងវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព
- តាមដាន ត្រួតពិនិត្យ កម្រិតកែប្រែរបស់ទណ្ឌិតនៅក្នុង **ម.យ.ន.** និងលើកសំណើសុំការបន្ធូរបន្ថយទោស ឬសុំការដោះលែងដោយមានលក្ខខណ្ឌផ្តល់ឱ្យដល់ទណ្ឌិត តាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាលតាមរយៈគណៈកម្មាធិការពិគ្រោះនិងវាយតម្លៃកម្រិតកែប្រែរបស់ទណ្ឌិតនៅ **ម.យ.ន.**
- អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ **ម.យ.ន.**
- រៀបចំនិងលើកគម្រោងថវិកាសម្រាប់ដំណើរការការងាររបស់ **ម.យ.ន.**
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារដែលសម្រេចបានរបស់ **ម.យ.ន.** ជូនក្រសួងតាមកាលកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន។/.

**មាត្រា៦ ..**

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការពិគ្រោះនិងវាយតម្លៃកម្រិតកែប្រែរបស់ទណ្ឌិតនៅ **ម.យ.ន.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា៧ ..**

បែបបទនៃការផ្តល់សេវាព្យាបាល ថែទាំសុខភាពដល់អនីតិជននៅ **ម.យ.ន.** ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានិងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## ជំពូកទី៣
## រចនាសម្ព័ន្ធរបស់ ម.យ.ន.

**មាត្រា៨ ..**

**ម.យ.ន.** នៅក្នុងព្រះរាជាណាចក្រកម្ពុជាចំណុះឱ្យអគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរចនាសម្ព័ន្ធស្មើនាយកដ្ឋាន។

**មាត្រា៩ ..**

ការសាងសង់ ការកំណត់ទីតាំង ការផ្លាស់ប្តូរទីតាំង ការដាក់ឈ្មោះ ការផ្លាស់ប្តូរឈ្មោះ និងការរំលាយមណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា១០ ..**

**ម.យ.ន.** ដឹកនាំដោយប្រធាន១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងអមដោយអនុប្រធានមួយចំនួនតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា១១ ..**

**ម.យ.ន.** មានការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ នៃ **ម.យ.ន.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា១២ ..**

ឯកសណ្ឋានរបស់មន្ត្រីនិងបុគ្គលិកបម្រើការងារនៅមណ្ឌលយុវនីតិសម្បទា និងអនីតិជនជាប់ឃុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៤
## ប្រភពធនធានថវិការបស់ ម.យ.ន.

**មាត្រា១៣ ..**

**ម.យ.ន.** មានប្រភពធនធានថវិកាពីថវិកាជាតិនៅក្នុងក្របខណ្ឌកញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់អនុវត្តសកម្មភាពរបស់ខ្លួន ស្របតាមគោលការណ៍និងនីតិវិធីច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ។

**ម.យ.ន.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១៤ ..**

របបគោលនយោបាយសម្រាប់អនីតិជនជាប់ឃុំដែលមានអាយុពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ និងនីតិជនជាប់ឃុំដែលមានអាយុពី១៨(ដប់ប្រាំបី)ឆ្នាំ ត្រូវបានរក្សាទុករហូតដល់អាយុក្រោម២៤(ម្ភៃបួន)ឆ្នាំ នៅ **ម.យ.ន.** ត្រូវអនុវត្តអនុក្រឹត្យលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៧ នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៦ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋរហូតដល់មានអនុក្រឹត្យថ្មីមកជំនួស។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វង សូត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ